# ចុះបើគ្មានលោក សម រង្ស៊ី ?

សំនួរនេះ សមនឹងលើកយកមកពិចារណា ក្នុងគំនិត រកការពិត អំពីវត្តមាន ជាប្រយោជន៏ របស់លោក សម រង្ស៊ី នៅក្នុងឆាកនយោបាយនៅក្នុងស្រុកខ្មែរ។ គេអាចទុកលោក សម រង្ស៊ី ជានយជន (អ្នកនយោបាយ) ជើងចាស់ម្នាក់ នៅមានប្រជាប្រិយភាព ទោះបីលោក បានធ្វើកំហុស មួយចំនួននៅក្នុង សកម្មភាពនយោបាយរបស់លោក។ តែទោះបីអ្នកប្រឆាំងនឹងលោក សម រង្ស៊ី ចង់ឬមិនចង់ តែសព្វថ្ងៃ វាមានឃើញតែគាត់ម្នាក់ នៅមានធ្វើសកម្មភាពមួយចំនួន មានទម្រង់សកម្ម ជាការប្រឆាំងនឹងរបបផ្តាច់ការនៅភ្នំពេញ ដែលទាក់ទាញចំណាប់អារម្មណ៍ជាតិ និង អន្តរជាតិ។ អង្គហេតុនេះឯងដែលរបបនៅភ្នំពេញ នៅតែផ្តោតការវាយប្រហារ ជាប្រព័ន្ធលើលោក សម រង្ស៊ី ហើយទុកគាត់ជាគ្រោះថ្នាក់អច្ចាសន្ន សំរាប់របប។ គំនិតនេះ មិនមែនមានសេចក្តីថា វាគ្មានអ្នកប្រឆាំងដទៃទៀត ដែលកំពុងធ្វើសកម្មភាព ចេញមុខក្តី បិទមុខក្តី ប្រឆាំងនឹងរបបភ្នំពេញ តែសកម្មភាពភាគច្រើន វាហាក់បីគ្មានសន្ទុះជា សេចក្តីសង្ឃឹមជឿបាន ហើយ ជួនកាល វាទៅជាអំពើថែទាំរបស់របបទៅវិញ។ ក៏ដូចគ្មានឹង សកម្មភាពសព្វថ្ងៃរបស់លោក សម រង្ស៊ី ដែរ វាកំពុងនៅលើដែនសីមារអិល បើជំហានគាត់ រំអិលតែបន្តិច វានឹងក្លាយជា ជំនួយដល់របបនៅភ្នំពេញទៅវិញ ដូចដែលគាត់ ធ្លាប់បានធ្វើពីអតីតកាល។ ពេលឥឡូវនេះឯង ដែលគេត្រូវការអ្នកដឹកនាំរវៀស !៕